ស្ថានទូតបារាំង

ប្រចាំព្រះរាជាណាចក្រកម្ពុជា

❖ ❖

ការិយាល័យពត៌មាន

❖

# សន្ទរកថារបស់លោក ហ្សាក់ ហ្ស៊ីរ៉ាក់ ប្រធានាធិបតីនៃសាធារណៈរដ្ឋបារាំង ក្នុងឱកាសលៀងសាយភោជន៍ថ្វាយជាកិត្តិយស ចំពោះព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង ព្រះរាជអគ្គមហេសី នាពេលព្រះរាជទស្សនកិច្ចរបស់ព្រះអង្គនៅប្រទេសបារាំង

(រដ្ឋធានី Paris - វិមាន Elysée -ថ្ងៃទី២២ មេសា ១៩៩៦)

(បកប្រែក្រៅផ្លូវការ)

**ព្រះករុណា**

**ព្រះរាជអគ្គមហេសី**

នេះជាពេលដ៏សែនរំជួលចិត្ត និងសប្បាយរីករាយ ដែលយើងស្គាល់នាល្ងាចនេះ ហើយក៏ជាឱកាសដើម្បីសម្តែងនូវមិត្តភាពមួយដែលជាចំណងដ៏យូរអង្វែង និងជ្រាលជ្រៅរវាងប្រទេសយើងទាំងពីរ ។ មិត្តភាព សេចក្តីស្រឡាញ់និងកោតសរសើរចំពោះសម្តេចទាំងពីរព្រះអង្គ សេចក្តីស្រឡាញ់និងកោតសរសើរចំពោះការតស៊ូនិងព្រហ្មចារិភាពរបស់ព្រះអង្គ ការចាប់ចិត្តចំពោះអរិយធម៌ដែលព្រះអង្គតែងតែគង់ប្រថាប់ជានិមិត្តរូបនិងការពារ ។

នាថ្ងៃទី២៤ មិថុនា ១៩៦៤ ដើម្បីធ្វើបដិសន្ថារកិច្ចថ្វាយព្រះអង្គទាំងពីរ លោកឧត្តមសេនីយ៍ de Gaulle បានរកឃើញពាក្យដ៏សែនត្រឹមត្រូវសំរាប់សម្តែងនូវមិត្តភាពដ៏សែនជិតស្និទ្ធរវាងព្រះរាជាណាចក្រកម្ពុជានិងបារាំង : "មនោសញ្ចេតនារវាងកម្ពុជានិងបារាំងក៏ដូចជាផលប្រយោជន៍រួមរបស់ប្រទេសយើងទាំពីរ មានតែមួយគត់ ឥតមានប្រទេសណាមួយទៀតទេនៅភាគអាស៊ីដែលស្គាល់ភាពនេះជាមួយប្រទេសបារាំង" "នេះជាពន្ធភាពយ៉ាងច្រើនដែលជាចំណងរវាងប្រទេសយើងទាំងពីរ" ។ នេះក៏ជាភាពចាប់ចិត្តទៅវិញទៅមករវាងអរិយធម៌របស់ប្រទេសយើងទាំងពីរ ។

តែលោកឧត្តមសេនីយ៍ក៏បានមានប្រសាសន៍អំពីភ្លើងសង្គ្រាមដែលកំពុងតែឆាបឆេះមកជិតប្រទេសកម្ពុជានាឆ្នាំនោះ ហើយនាពេលនោះខ្មែរក៏បែរទៅរកមិត្តបារាំងដើម្បីការគាំទ្រ ដូចជា១សតវត្សកន្លងទៅដែរ ។

ពីរឆ្នាំបន្ទាប់មកលោកឧត្តមសេនីយ៍ បានធ្វើសុន្ទរកថាដ៏ល្បីល្បាញមួយនៅស្តាតអូឡាំពិច នារាជធានីភ្នំពេញ ប្រសាសន៍របស់លោកនាពេលនោះនៅតែដក់ជាប់ក្នុងអារម្មណ៍របស់យើង ។ នាពេលនោះលោកបានមានប្រសាសន៍ពីការយល់ឃើញរបស់លោកចំពោះសង្គ្រាមនៅវៀតណាមនិងសេចក្តីបារម្ភអំពីអនាគតរបស់ប្រទេសកម្ពុជា ។ ជាការសោកស្តាយណាស់ តែប្រវត្តិសាស្ត្របានអោយយើងឃើញនូវភាពត្រឹមត្រូវដ៏អស្ចារ្យនៃពាក្យសំដីរបស់លោក ។

បន្តិចក្រោយមករដ្ឋប្រហារដ៏ខុសច្បាប់មួយ ការនិរទេសរបស់ព្រះអង្គ និងភ្លើងសង្គ្រាមដែលឆាបឆេះមកលើកម្ពុជាបានធ្វើអោយប្រជារាស្ត្រខ្មែរទទួលវាសនាដ៏អាក្រក់ ។ បន្តិចម្តងៗកម្ពុជាធ្លាក់ចូលក្នុងភាពមហន្តរាយ ។ អ្នកការទូតនៃស្ថានទូតរបស់យើងត្រូវបានចាកចេញពីទីក្រុងភ្នំពេញ ដោយសេចក្តីក្រៀមក្រំក្នុងចិត្តបំផុតកាលពី២១ឆ្នាំកន្លងទៅនេះ ។ នាថ្ងៃនោះបារាំងត្រូវបានចាកចេញពីកម្ពុជាទាំងការបង្ខំចិត្ត ក្រោយពីបានស្គាល់ក្នុងអំលុងពេល១សតវត្សនូវសេចក្តីសុខសប្បាយនិងវិបត្តិនៃប្រវត្តិសាស្ត្ររួមគ្នាមួយ ។

ជានិច្ចជាកាលបារាំងតែងតែនឹកដល់កម្ពុជា ។ ក្នុងសោកនាដកម្មពេលដែលខ្មែរជិតវិនាសលើសលុបស្លាប់ក្រោមបាតដៃដ៏លីលារបស់ខ្មែរក្រហម និងរបបប្រល័យពូជសាសន៍របស់វា បារាំងនាពេលនោះមានចិត្តអាណិតអាសូរដល់ប្រជារាស្ត្ររបស់ព្រះអង្គ ។ បារាំងក៏បានទទួលលើដីខ្លួនជនរួមជាតិរបស់ព្រះអង្គរាប់ម៉ឺននាក់ ។ នៅលើឆាកអន្តរជាតិទាំងឡាយបារាំងតែងតែការពារព្រះរាជតំរិះរបស់ព្រះករុណាដើម្បីឧត្តមប្រយោជន៍ប្រទេសខ្មែរ ។ បារាំងក៏បានអំពាវនាវដល់ភាគីខ្មែរទាំងអស់ឱ្យស្វែងរកមធ្យោបាយដើម្បីសន្តិភាពក្រោមព្រះរាជកិច្ចដឹកនាំរបស់ព្រះករុណា ។

ក្រោយពីបានចរចាអំលុងពេល២ឆ្នាំ ២ខែ និង២២ថ្ងៃ សេចក្តីព្រមព្រៀងត្រូវបានចុះហត្ថលេខា ។ នាទីក្រុង **Paris** នេះហើយដែលសន្តិភាពមួយសំរាប់កម្ពុជាបានបង្កើតឡើងក្រោមការត្រួតពិនិត្យរបស់អង្គការសហប្រជាជាតិ ។

យុគសម័យថ្មីមួយបានចាប់ផ្តើមចំពោះព្រះភក្ត្រព្រះអង្គ ។ ក្រោយពីបានទទួលទុក្ខវេទនាដ៏សែនជូចត់នៃប្រវត្តិសាស្ត្រ ប្រជារាស្ត្រខ្មែរបានចាប់ផ្តើមមានសេចក្តីសង្ឃឹមដោយជ្រកក្រោមម្លប់របស់ព្រះអង្គ ហើយបានចាប់ផ្តើមស្តារប្រទេសឡើងវិញ ។ ទាំងអស់នេះក៏ជាស្នាព្រះហស្ត សេចក្តីអង់អាចនិងជំនឿដ៏មុតមាំរបស់ព្រះករុណាចំពោះជាតិខ្មែរដែរ ដែលព្រះអង្គតែងតែខំប្រឹងប្រែងដើម្បីប្រត្យាស្ថាបនាកម្ពុជាក្នុងឯករាជភាព អធិបតីភាព និងឯកភាពជាតិ ។

ក្នុងប្រវត្តិសាស្ត្រកម្ពុជា ក្រោយពីភាពជុនដាប តែងតែមានភាពរុងរឿង ។ ជាពិសេសខ្ញុំនឹកដល់សតវត្សទី១២និង១៣ ពេលដែលមហានគរខ្មែរលាតត្រដាងនិងជះឆ្ងាយអារិយធម៌និងឥទ្ធិពលរបស់ខ្លួន ។ ប្រាសាទអង្គរបង្ហាញឱ្យពិភពលោកឃើញកិត្យានុភាពប្រវត្តិសាស្ត្រដ៏យូរលង់និងអចិន្ត្រៃយ៍ភាពនៃវិរកម្មខ្មែរ ហើយនៅប្រាសាទអង្គរក៏បារាំងនិងខ្មែរបានចង និងចងឡើងវិញនូវកិច្ចសហប្រតិបត្តិការមួយជាគំរូសម្រាប់គេដ៏ទៃទៀត ។ ប្រជារាស្ត្រនិងអរិយធម៌ខ្មែរជាប្រជារាស្ត្រនិងអរិយធម៌មួយក្នុងចំណោមប្រជារាស្ត្រនិងអរិយធម៌ដ៏ទៃទៀតដែលមិនងាយអាចរលាយសាបសូន្យបានឡើយ ។

ឥឡូវកម្ពុជាទើបបន្តិចម្តងៗ និងផ្សះផ្សាស្នាមរបួសរបស់ខ្លួន ។ វិបត្តិនិងការមហន្តរាយកន្លងមកនិងភាពមិនទាន់មានលំនឹងនៃប្រទេសរបស់ព្រះអង្គ បង្ហាញឱ្យឃើញអ្វីដែលប្រទេសរបស់ព្រះអង្គ ត្រូវពុះពារដើម្បីស្តារជាតិឡើងវិញ ។

ប្រទេសខ្មែរមិនឯកកោទេ ។ អង្គការសហប្រជាជាតិបានជួយអនុវត្តនៃកិច្ចព្រមព្រៀងក្រុង **Paris** និងរៀបចំការបោះឆ្នោតនាឆ្នាំ១៩៩៣ដោយជោគជ័យ ។ បារាំងក៏បានរួមចំណែកយ៉ាងសកម្ម ។

ឥឡូវនេះបារាំងបានជួយយ៉ាងខ្នះខ្នែងដើម្បីបោសសំអាតមីនពីទឹកដីជនបទ ដែលនៅទីនោះមីនរាប់លានគ្រាប់នៅតែបង្ករគ្រោះថ្នាក់ដល់ប្រុស ស្ត្រី និងកុមារ យ៉ាងច្រើនក្រោយពីចប់សង្គ្រាម៥ឆ្នាំកន្លងមកហើយ ។ ដោយគិតដល់វិបត្តិនៅកម្ពុជា បារាំងបានផ្តួចផ្តើមគំនិតនៃកិច្ចសន្យាអន្តរជាតិមួយដើម្បីហាមឃាត់ការប្រើប្រាស ដោយឥតរៀនខ្មាស់ និងស ប់ខ្ពើមនូវគ្រាប់មីន។

បារាំងចង់ជួយស្តារប្រទេសរបស់ព្រះអង្គក្នុងគ្រប់វិស័យ ។ សង្គមខ្មែរទាំងមូលត្រូវតែធ្វើនិតិសម្បទាវិញក្រោមព្រះរាជកិច្ចដឹកនាំរបស់ព្រះអង្គ តាមបែបប្រជាធិបតេយ្យ និងតាមផ្លូវព្រះពុទ្ធសាសនា ។ រយៈពេល៥ឆ្នាំកន្លងមកនេះ ខ្មែរបានចាប់ផ្តើមយកច្បាប់ផលប្រយោជន៍ជាតិ និងសេដ្ឋកិច្ចដែលមានទម្រង់ត្រឹមត្រូវជាមូលដ្ឋាន ហើយបារាំងក៏បានជួយ និងបន្តជំនួយសំរាប់វិស័យខាងលើនេះដោយជួយអភិវឌ្ឍន៍ ឧត្តមសិក្សា និងអប់រំ ។

ខ្ញុំសូមសម្តែងនូវសេចក្តីគាំទ្ររបស់បារាំងចំពោះព្រះករុណាដែលព្រះអង្គខំប្រឹងប្រែងការពារបរិស្ថាន ជាពិសេសដើម្បីរក្សាព្រៃឈើខ្មែរ ។ គេធ្លាប់តែនិយាយថាការរក្សាធម្មជាតិជាកង្វល់របស់ប្រទេសអ្នកមាន ។ ប៉ុន្តែនៅកម្ពុជា ដូចព្រះអង្គបានមានព្រះបន្ទូល បញ្ហាបរិស្ថានធ្លាក់ចូលក្នុងភាពអាសន្នហើយ ការកាប់ព្រៃឈើបាននាំមកនូវវិបត្តិយ៉ាងធ្ងន់ដល់ធម្មជាតិនៅស្រុកខ្មែរ ។ ព្រះករុណាក៏បានខំប្រឹងប្រែងយ៉ាងអស្ចារ្យដើម្បីការពារ និងរក្សាធម្មជាតិដើម្បីអនាគតនៃប្រជារាស្ត្រនិងប្រទេសរបស់ព្រះអង្គ ។

លើឆាកអន្តរជាតិ បារាំងក៏ជួយរួមចំណែកជាមួយកម្ពុជាដែរ ។ នៅលើឆាកសហគមន៍ Europe បារាំងក៏បានផ្តល់ការគាំទ្រចំពោះកម្ពុជាដែរ ដោយដាស់តឿនដៃគូរបស់ខ្លួនឱ្យមកជួយប្រទេសខ្មែរ ហើយបារាំងក៏គាំទ្រឱ្យកម្ពុជាក្លាយទៅជាសមាជិក ASEAN ដើម្បីឱ្យកម្ពុជាអាចទាញផលប្រយោជន៍គ្រប់វិស័យពីសមាជិកភាពរបស់ខ្លួននាអនាគត។

ប៉ុន្មានសប្តាហ៍កន្លងទៅនេះ ខ្ញុំបានធ្វើសេចក្តីថ្លែងការមួយនៅទីក្រុង Singapour ដើម្បីបង្ហាញនូវបំណងរបស់បារាំងក៏ដូចជាបំណងរបស់សហគមន៍ Europe ដើម្បីកិច្ចសហប្រតិបត្តិការជាមួយប្រទេសនៅអាស៊ី ខ្មែរក៏ត្រូវទទួលតំណែងរបស់ខ្លួនក្នុងកិច្ចសហប្រតិបត្តិការនេះដែរ ។ ព្រះករុណាទ្រង់ជ្រាបថាប្រទេសរបស់ព្រះអង្គជាប្រទេសមួយដែលបារាំងចាត់ទុកជាគូសន្ទនាដ៏សំខាន់របស់ខ្លួនក្នុងតំបន់អាស៊ី ។ ទូលព្រះបង្គំក៏យល់ច្បាស់ពីសន្តានព្រះទ័យរបស់ព្រះអង្គចំពោះវប្បធម៌បារាំង និងព្រះទ័យរបស់ព្រះអង្គដែលចង់ឱ្យកម្ពុជាស្ថិតនៅក្នុង "គ្រួសារនៃប្រទេសដែលប្រើភាសារបារាំង" ។

បារាំងដែលធ្លាប់តែការពារកម្ពុជាដើម្បីសេរីភាព ឯកភាពជាតិ និងកិត្តិយសរបស់ខ្មែរ បារាំងដែលបានចាត់ទុកប្រទេសរបស់ព្រះអង្គជាមិត្តដ៏ជិតស្និទ្ធ ហើយក៏បានថ្វាយនូវមិត្តភាពដែលមិនអាចសាបសូន្យចំពោះព្រះអង្គ មានសេចក្តីដឹងគុនចំពោះព្រះរាជហឫទ័យរបស់ព្រះអង្គ ។ ប្រទេសបារាំងមានជំនឿចំពោះអនាគតនៃប្រជារាស្ត្រខ្មែរ ។

ទូលព្រះបង្គំសូមលើកកែវនេះស្វាគមន៍ចំពោះមិត្តភាពរវាងខ្មែរបារាំង ហើយសុំសន្យាជួយប្រជាជាតិខ្មែរដ៏ល្បីល្បាញ ដើម្បីស្វែងរក ការអភិវឌ្ឍន៍ និងវឌ្ឍនភាព ។

ទូលព្រះបង្គំសូមលើកកែវនេះដោយរីករាយដើម្បីថ្វាយនូវគារវភក្តិ ដ៏ជ្រាលជ្រៅជាទីបំផុតដល់ព្រះករុណា ព្រះនរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជអគ្គមហេសី នរោត្តមមុនិនាថ សីហនុ ។ ទូលព្រះបង្គំសូមប្រសិទ្ធិពរជ័យថ្វាយព្រះអង្គទាំងពីរ សូមឱ្យព្រះអង្គមានសុខភាពបរិបូរណ៍ដើម្បីគង់ប្រថាប់ជាតំណាង នៃបំណង និងគតិបណ្ឌិត របស់ប្រជារាស្ត្រខ្មែរ ។ ខ្ញុំសូមជូនពរដល់ប្រជារាស្ត្រខ្មែរទាំងអស់ឱ្យបានសន្តិភាព សេចក្តីសុខ និងវិបុលភាព ។ ខ្ញុំសូមលើកកែវនេះចំពោះមិត្តភាពដែលមានអាយុជាងមួយសតវត្សមកហើយរវាងប្រទេសយើងទាំងពីរ ហើយដែលមានលោកឧត្តមសេនីយ៍ de Gaulle និងព្រះអង្គជានិមិត្តរូប ។

**ជ័យយោ! កម្ពុជា**

**ជ័យយោ! ប្រទេសបារាំង**

**ជ័យយោ! មិត្តភាពបារាំងខ្មែរ**

AMBASSADE DE FRANCE AU CAMBODGE

REPUBLIQUE FRANCAISE

បកប្រែក្រៅផ្លូវការ

ដោយ

ការិយាល័យពត៌មាននៃស្ថានទូតបារាំង

ប្រចាំព្រះរាជាណាចក្រកម្ពុជា